**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ**

លេខ ៣៣៥៣ កសក

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៥

**សូមគោរពជូន**

- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
- **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាប្រធានក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ**
- **ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃព្រឹទ្ធសភា**
- **ឯកឧត្តមប្រធានគណៈកម្មការផែនការ សេដ្ឋកិច្ច វិនិយោគ កសិកម្ម បរិស្ថាន និងអភិវឌ្ឍន៍ជនបទនៃរដ្ឋសភា**
- **ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងផែនការ**
- **ឯកឧត្តម គុយ សុផល ទេសរដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការទូទៅអមក្រសួងព្រះបរមរាជវាំង**
- **ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
- **ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាធម្មពោធិសាល ប្រធានព្រឹទ្ធសភា**
- **ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាពញាចក្រី ប្រធានរដ្ឋសភា**
- **ឯកឧត្តមនាយកខុទ្ទកាល័យ សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី**
- **ឯកឧត្តមនាយកខុទ្ទកាល័យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ គាត ឈន់**

**កម្មវត្ថុ** ÷ របាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែឧសភា ឆ្នាំ២០១៥** និងទិសដៅអនុវត្តបន្ត ។

ន័យដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមផ្ញើជូនឯកឧត្តម នូវរបាយការណ៍ស្តីពីសភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ **ប្រចាំខែឧសភា ឆ្នាំ២០១៥** ចំនួន០១ច្បាប់ ដើម្បីជូនជ្រាបជាសេចក្តីរាយការណ៍ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ជ្រាលជ្រៅអំពីខ្ញុំ ។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**យុន្ត ភ្ញុំថង**

**ចម្លងជូន**

- គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង
- ឯកសារ កាលប្បវត្តិ


អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ :(០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

# របាយការណ៍
# ស្តីពី
# សភាពការណ៍កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
# ប្រចាំខែឧសភា ឆ្នាំ២០១៥ និងទិសដៅអនុវត្តបន្ត

## I- សភាពការណ៍រួម

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានអង្គភាពជំនាញនិងមន្ទីរកសិកម្មរាជធានី ខេត្ត ជាសេនាធិការ បានខិតខំបំពេញភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវដោយតម្រង់ទិសដៅតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ដ៏ត្រចះត្រចង់របស់រាជរដ្ឋាភិបាលយ៉ាងយកចិត្តទុកដាក់។ មកទល់ពេលនេះ ស្ថានភាពទឹកភ្លៀងនៅមិនទាន់ធ្លាក់រាយប៉ាយគ្រប់តំបន់ទូទាំងប្រទេសនៅឡើយទេ ដែលធ្វើឲ្យការងារបង្កបង្កើនផលដំណាំស្រូវសម្រេចបាន១៦% លើសឆ្នាំមុន០,៤២% បើប្រៀបធៀបរយៈពេលដូចគ្នា។

ជារួម នៅក្នុងខែឧសភានេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវវស្សាឆ្នាំ២០១៥មានសភាពលឿនជាងឆ្នាំមុនប្រមាណ៣៥.១៧៧ហិកតា។ បច្ចុប្បន្ន ប្រជាកសិករបាននិងកំពុងខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប ព្រោះ និងដកស្ទូង ដើម្បីឲ្យទាន់រដូវកាលដាំដុះ។ ដោយឡែក ចំពោះជំងឺឆ្លងសត្វ និងជំងឺឆ្លងរាតត្បាតផ្សេងៗលើសត្វពាហនៈពុំមានចោទជាបញ្ហាទេ។ រីឯលទ្ធផលនិងសកម្មភាពការងារសំខាន់ៗតាមផ្នែកផ្សេងៗទៀតដែលសម្រេចបានក្នុងខែឧសភា ឆ្នាំ២០១៥ នេះមានដូចខាងក្រោម៖

## II- លទ្ធផលសម្រេចបានតាមបណ្តាផ្នែក

### ១ ផ្នែកដាំដុះ

#### ១.១ លទ្ធផលការងារបង្កបង្កើនផលដំណាំស្រូវរដូវវស្សាឆ្នាំ២០១៥

- ផ្ទៃដីភ្ជួររាស់សរុបចំនួន៦៤៥.៣៥៣ហិកតា ក្នុងនោះភ្ជួររាស់ដោយគោ ក្របីចំនួន៣២.៩៤១ហិកតា ស្មើនឹង ៥,១០% និងគ្រឿងយន្តចំនួន៦១២.៤១២ហិកតា ស្មើនឹង៩៤,៩០% លើសឆ្នាំមុនចំនួន៣.២៥៧ហិកតា

- ផ្ទៃដីសាបសរុបចំនួន៣.២៧៤ហិកតា លើសឆ្នាំមុនចំនួន៤១៥ហិកតា

- ផ្ទៃដីសន្ទូងនិងពង្រោះសម្រេចបានចំនួន៤១០.៧៤២ហិកតា ស្មើនឹង១៦% នៃផែនការ២.៥៦៧.១៣០ហិកតា លើសឆ្នាំមុនចំនួន៥.១៧៧ហិកតា ក្នុងនោះស្រូវតាមប្រភេទមាន៖

+ ស្រូវស្រាលចំនួន១៧៦.០០៤ហិកតា ក្នុងនោះ ស្រូវបង្កើនរដូវចំនួន៣២.៦៨១ហិកតា លើសឆ្នាំមុនចំនួន៣៦.២៦០ហិកតា

+ ស្រូវកណ្តាលចំនួន១០៤.១១៦ហិកតា តិចជាងឆ្នាំមុនចំនួន១.៤៧៦ហិកតា

+ ស្រូវធ្ងន់ចំនួន៩៤.៩៥៤ហិកតា លើសឆ្នាំមុនចំនួន៤.៥៣៣ហិកតា

+ ស្រូវចម្ការចំនួន៤.៤២៥ហិកតា តិចជាងឆ្នាំមុនចំនួន២.៦៦៣ហិកតា

+ ស្រូវឡើងទឹកចំនួន៣១.២៤៣ហិកតា តិចជាងឆ្នាំមុនចំនួន១.៤៧៧ហិកតា។

#### ១.២ ដំណាំរួមផ្សំ និងដំណាំឧស្សាហកម្ម

- ផ្ទៃដីដំណាំរួមផ្សំសម្រេចបានចំនួន៣១២.១៥២ហិកតា ស្មើនឹង៥៥,៩៨% នៃផែនការ៥៥៧.៦១៣ហិកតា តិចជាងឆ្នាំមុនចំនួន១៩.៩៥៦ហិកតា

- ផ្ទៃដីដំណាំឧស្សាហកម្មសម្រេចបានចំនួន២៥.១៥០ហិកតា ស្មើនឹង១៩,៣៨% នៃផែនការ១២៩.៧៤២ហិកតា តិចជាងឆ្នាំមុនចំនួន១៣.១៩៦ហិកតា។



អាស័យដ្ឋានលេខ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

### ១.៣ ស្ថានភាពនៃការនាំចេញអង្ករក្នុងរយៈពេល៥ខែដើមឆ្នាំ២០១៥

- បរិមាណអង្ករនាំចេញមានចំនួន២៤៣.០២៥តោន មានការកើនឡើងចំនួន៩៤.៧៦៣តោន លើស៥ខែដើមឆ្នាំ ២០១៤ ដែលនាំចេញបានតែ១៤៨.២៦២តោន។ ដោយឡែក បរិមាណអង្ករនាំចេញក្នុងខែឧសភា ឆ្នាំ២០១៥នេះ មានរហូតដល់៤១.៨៤២តោន ដែលមានការកើនចំនួន១៣.៨៧១តោន ច្រើនជាងបរិមាណនាំចេញក្នុងខែឧសភា ឆ្នាំ ២០១៤ ដែលនាំចេញបានតែ២៧.៩៧១តោន

- អង្ករកម្ពុជាបាននាំចេញទៅកាន់ទិសដៅចំនួន៤៦ប្រទេស(មានកំណើន២ប្រទេស ធៀបនឹង៤ខែដើមឆ្នាំ២០១៥) ក្នុងនោះប្រទេសចិនឈរលំដាប់ទី១(៦៨.៤៣៧តោន) ប្រទេសបារាំងឈរលំដាប់ទី២(២៩.៧១៧តោន) ប្រទេសប៉ូឡូញ ឈរលំដាប់ទី៣(២៦.៥១៣តោន) ប្រទេសម៉ាឡេស៊ីឈរលំដាប់ទី៤(២៣.២៥៤តោន) ប្រទេសនីឌ័រឡេនឈរលំដាប់ទី៥ (១៧.២០៨តោន) ប្រទេសអ៊ីតាលីឈរលំដាប់ទី៦(៩.៥៣៩តោន) សាធារណរដ្ឋឆេកឈរលំដាប់ទី៧(៩.០៣៥តោន) ប្រទេសប៊ែលហ្ស៊ិកឈរលំដាប់ទី៨(៨.៩៧៧តោន) ប្រទេសគ្រិចឈរលំដាប់ទី៩(៧.២៣៥តោន) និងប្រទេសអេស្ប៉ាញ ឈរលំដាប់ទី១០(៦.៥៥៣តោន)។ បរិមាណអង្ករដែលនាំចេញទៅកាន់ប្រទេសជាទិសដៅសហភាពអឺរ៉ុបទាំង២៥ប្រទេស មានបរិមាណសរុប១៤១.៧២០តោន(៥៨,៣%) ទិសដៅអាស៊ាន២ប្រទេសមានបរិមាណ២៥.៣០៨តោន(១០,៤%) និងទិសដៅផ្សេងទៀតទាំង១៩ប្រទេស មានបរិមាណ៧៥.៩៩៧តោន(៣១,៣%)។

## ២ ផ្នែកកៅស៊ូ

### ២.១ ការងារអាជីវកម្ម ផលិតកម្មកៅស៊ូ

| ល.រ | អង្គភាព | ផ្ទៃដីអាជីវកម្ម (ហ.ត) | ផ្ទៃដីដាំដុះនិងថែទាំ ២០០៣-២០១៣(ហ.ត) | ផលិតផលអនុវត្តបាន ដល់ខែនេះ (តោន) | បញ្ចេញលក់ ដល់ខែនេះ(តោន) |
|---|---|---|---|---|---|
| I-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មរដ្ឋ | | | | | |
| ១ | វិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៤០៦,៦០ | ៣៤៤,៣១ | ១៩២,១៣ | ១១១,៤៦ |
| **សរុប I** | | **៤០៦,៦០** | **៣៤៤,៣១** | **១៩២,១៣** | **១១១,៤៦** |
| II-ចម្ការកៅស៊ូកសិ-ឧស្សាហកម្មឯកជន | | | | | |
| ១ | ក្រុមហ៊ុន សុភក្តិនីកា អិនវេសមេន គ្រុប | ១០.៧១៩,២៧ | ៤.៤៣៤,០៩ | ៦.៨១៦,៧២ | ៥.៧១៥,៤៤ |
| ២ | ក្រុមហ៊ុន ស៊ីហ្វាប់ប៊េលីមីធីត (រតនគិរី) | ៧៨,៥៣ | ២.០៦៤,៣០ | ១៥២,៧៤ | - |
| ៣ | ក្រុមហ៊ុន ចម្ការកៅស៊ូតាប៉ាវ | ១.២៤១,៨០ | ១.០៨២,១២ | ៣៣១,០៤ | ២០០,០០ |
| ៤ | ក្រុមហ៊ុន ចម្ការកៅស៊ូបឹងកេត | ២.៦៤៥,៩៧ | ៣.០៦៥,៣៨ | ១.៩៥៤,៧៥ | ១.៤៧៥,២០ |
| ៥ | ក្រុមហ៊ុន ចម្ការកៅស៊ូមេមត់ខូអិលធីឌី | ៣.២៦៨,៧៤ | ៥.៣៤៦,៦៩ | ១.៤៧៩,៥២ | ៩៤៤,៥៦ |
| ៦ | ក្រុមហ៊ុន ស៊ីហ្វវីសស៍ (ស្នួល) | ១.៧៤៤,៧៨ | ២.៦៤១,៤៣ | ៧០៤,៥២ | ៤៦០,០០ |
| ៧ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ពាមជាំង) | ២.០២៩,៧០ | ១.២៣៧,៥៩ | ៦១៧,២២ | ២០៤,៦០ |
| ៨ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (ចម្ការអណ្តូង) | ៣.១១១,៦៥ | ១.២១៥,៥៥ | ៦២៥,៣៣ | ៣៥៥,៤០ |
| ៩ | ក្រុមហ៊ុន អានម៉ាឌីគ្រុប (មោសហែក) | - | ៨៧៥,៦៦ | - | - |
| ១០ | ក្រុមហ៊ុនក្រេក (ខេមបូឌា) ខូអិលធីឌី | ៣.៣៩៣,៥៥ | ២.៤៧៥,៣៨ | ១.៩៨៦,៥៨ | ១.៦០២,៦០ |
| **សរុប II** | | **២៨.២៣៣,៩៩** | **២៤.៤៣៨,១៩** | **១៤.៦៦៨,៤២** | **១០.៩៥៧,៨០** |
| III-ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | | | | | |
| ១១ | ក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ច | ៦.៤១៥,០០ | ១៥៥.២៦២,០០ | ១.៥៩១,០០ | ១.៥៩១,០០ |
| ១២ | ក្រុមហ៊ុន ចម្ការកៅស៊ូគ្រួសារ | ៧៣.៣៩៦,០០ | ៦៦.៩៥០,០០ | ២៥.៦៦០,០០ | ២៤.២៨៤,០០ |
| **សរុប III** | | **៧៩.៨១១,០០** | **២២២.២១២,០០** | **២៧.២៥១,០០** | **២៥.៨៧៥,០០** |
| **សរុប I+II+III** | | **១០៨.៤៥១,៥៩** | **២៤៦.៩៩៤,៥០** | **៤២.១១១,៥៥** | **៣៦.៩៤៤,២៦** |

### ២.២ ការងារវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា

- រៀបចំធ្វើតេស្តប្រៀបធៀបមន្ទីរពិសោធន៍ក្នុងស្រុកលើកទី៣១ ដើម្បីបញ្ជាក់គុណភាពកែច្នៃរបស់រោងចក្រក្រុមហ៊ុន ឡុង ស្រេង និងការធ្វើតេស្តកៅស៊ូ CV និងកៅស៊ូសន្លឹកសម្រាប់និស្សិតកម្មសិក្សា

- វិភាគសរីរៈទឹកជ័រលើចម្ការពិសោធន៍ក្លូន PB260, PB330 and IRCA209 ចុះស្រង់ ត្រួតពិនិត្យ និងបញ្ចូលទិន្នន័យចម្ការពិសោធន៍

- បើកវគ្គបណ្តុះបណ្តាលស្តីពីបច្ចេកទេសសម្រាប់ប្រមូលផលកៅស៊ូនិងការចៀរជ័រ ដែលមានអ្នកចូលរួមចំនួន៥៧នាក់ និងរៀបចំសិក្ខាសាលាស្តីពីការផ្ទេរបច្ចេកទេសដើម្បីអភិវឌ្ឍន៍កៅស៊ូគ្រួសារនៅកម្ពុជា

- ដឹកនាំការសរសេរសារណារបស់និស្សិតសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងសាកលវិទ្យាល័យស្វាយរៀង

- បញ្ជូនមន្ត្រីចំនួន០២រូបទៅចូលរួមប្រជុំស្តីពី "IRRDB Plant Breeders Meeting" នៅប្រទេសថៃ។

គួរកត់សម្គាល់ផងដែរថា គណៈប្រតិភូជាន់ខ្ពស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានទៅចូលរួមក្នុងសម័យប្រជុំពិសេសនៃសន្និបាតថ្នាក់រដ្ឋមន្ត្រីសមាគមបណ្តាប្រទេសផលិតកៅស៊ូធម្មជាតិ(ANRPC: Association of Natural Rubber Producing Countries) ដែលបានប្រព្រឹត្តទៅពីថ្ងៃទី៧-៨ ខែឧសភា ឆ្នាំ២០១៥ នៅទីក្រុងគូឡាលំពួរ ប្រទេសម៉ាឡេស៊ី។

## ៣ ផ្នែកផលិតកម្មនិងបសុព្យាបាល

### ៣.១ ការងារវិទ្យាស្ថានស្រាវជ្រាវផលិតកម្មសត្វ

- ជ្រូកសរុបចំនួន២៣២ក្បាល នៅក្នុងស្ថានីយពិសោធន៍ពូជជ្រូក ក្នុងនោះជ្រូកបាចំនួន៩ក្បាល ជ្រូកមេចំនួន៩១ក្បាល និងកូនជ្រូកចំនួន១៣២ក្បាល

- គោសរុបចំនួន១៥៩ក្បាល នៅក្នុងស្ថានីយចិញ្ចឹមគោ ក្នុងនោះគោបាចំនួន៤ក្បាល គោប្រាម៉ាន់កាត់ចំនួន៣៥ក្បាល គោជំទង់ចំនួន៣៤ក្បាល គោបៅដោះចំនួន៤៤ក្បាល និងគោកំផែងសែនចំនួន៤២ក្បាល

- វិទ្យាស្ថានបានខិតខំពង្រឹងសកម្មភាពពិសោធន៍ស្រាវជ្រាវដូចខាងក្រោម៖

+ ធ្វើសំណើសុំលក់កូនជ្រូកគ្រប់អាយុត្រូវលក់និងមេបាជម្រុះ

+ រៀបចំសកម្មភាពគម្រោងគាំទ្រដោយសហភាពអឺរ៉ុបទាក់ទងនឹងការងារកែច្នៃទឹកមេជីវិតគោ

+ លើកសំណើទៅភាគីចិនដើម្បីបង្កើតមជ្ឈមណ្ឌលបង្កាត់សិប្បនិម្មិតគោ មន្ទីរពិសោធន៍វិភាគចំណីសត្វ មន្ទីរពិសោធន៍សេនេទិច និងមន្ទីរពិសោធន៍កាកសំណល់ថ្នាំ

+ រៀបចំស្នើសុំទិញឧបករណ៍វិភាគចំណីតាមរយៈគម្រោងសហភាពអឺរ៉ុបនិងគម្រោង SPS។

### ៣.២ ការចាក់ថ្នាំបង្ការជំងឺឆ្លងសត្វ

- ចាក់ថ្នាំការពារជំងឺឆ្លងលើគោ-ក្របី ជំងឺសារទឹកចំនួន២១.៣៩០ក្បាល ជំងឺអុតក្តាមចំនួន២១១ក្បាល និងជំងឺបូសខ្យល់ចំនួន១.២៥៨ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើសត្វជ្រូក ជំងឺសារទឹកចំនួន១០.៣៤៧ក្បាល ជំងឺប៉េស្តចំនួន១៩.២៩៩ក្បាល ជំងឺសាល់ម៉ូណេឡូសចំនួន១០.៧០៨ក្បាល ជំងឺអុតក្តាមចំនួន២.៤៧៩ក្បាល ជំងឺអូហ្យេស្គីចំនួន៤.៥៧២ក្បាល ជំងឺកញ្ជ្រឹលចំនួន៧៨០ក្បាល ជំងឺជាតិដែកចំនួន២.៩៩៦ក្បាល ជំងឺរាគកូនជ្រូកចំនួន២.៩៦០ក្បាល ជំងឺផ្លូវដង្ហើមចំនួន២.៣៤០ក្បាល

- ចាក់ថ្នាំការពារជំងឺឆ្លងលើបក្សី ជំងឺអុតចំនួន៩០.៥១២ក្បាល ជំងឺញីវកាសចំនួន១១៥.៨៦១ក្បាល ជំងឺអាសន្នរោគចំនួន៥៩.៨២៩ក្បាល ជំងឺហ្គុមបូរូចំនួន៧១ក្បាល និងជំងឺប៉េស្តទាចំនួន១២៩.០១៣ក្បាល។

### ៣.៣ ការងារវិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល

- ចុះអង្កេតស្រាវជ្រាវកន្លែងផ្ទុះជំងឺអុតក្តាម សារទឹក បូសខ្យល់ និងជំងឺប៉េស្តជ្រូក

- រៀបចំធ្វើឲ្យប្រសើរឡើងការងារតាមដានព័ត៌មានសុខភាពសត្វ

- អង្កេតស្រាវជ្រាវ តាមដានឃ្លាំមើល និងយកវត្ថុវិភាគ ស្តីពីជំងឺផ្តាសាយបក្សីនិងជំងឺទូទៅនៅតាមខេត្ត-រាជធានី

- បានពិនិត្យវត្ថុវិភាគសរុបចំនួន១.២៥៧សំណាក និងផ្នែកសរីរោគសាស្ត្រសរុបចំនួន៨ក្បាល

- ចុះផ្សព្វផ្សាយអត្ថប្រយោជន៍ឡជីវឧស្ម័ន និងផលិតឡជីវឧស្ម័នសរុបចំនួន២៦៣ឡ។

### ៣.៤ ការអនុវត្តវិធានបសុពេទ្យ

- ចុះធ្វើការបាញ់ថ្នាំសម្លាប់មេរោគនៅកន្លែងចិញ្ចឹមគោចំនួន៣៣លើក ជ្រូកចំនួន១៨៨លើក មាន់ចំនួន៣៥៥លើក ទាចំនួន១.៦៤១លើក កន្លែងពិឃាតមាន់ចំនួន៣៧លើក កន្លែងលក់មាន់ចំនួន១៣លើក ទ្រុងចិញ្ចឹមចំនួន៤៣០លើក បរិវេណភូមិចំនួន៧១លើក សត្តឃាតដ្ឋានចំនួន៨០លើក និងផ្លូវជាតិចំនួន៤លើក

- ក្រុមអន្តរាគមន៍របស់នាយកដ្ឋានផលិតកម្មនិងបសុព្យាបាលសហការជាមួយមន្ទីរកសិកម្មរាជធានី-ខេត្ត បានបន្តចុះត្រួតពិនិត្យនិងបង្ក្រាបបទល្មើសចលនាដឹកជញ្ជូនសត្វនិងផលិតផលមានដើមកំណើតពីសត្វជាប់ជាប្រចាំ ជាពិសេសបណ្តាខេត្តនៅជាប់ព្រំដែន។ ក្នុងខែកន្លងមកនេះបង្ក្រាបបានចំនួន១៥ករណី ដោយអនុវត្តតាមនីតិវិធីនិងវិធានបច្ចេកទេស។

## ៤ ផ្នែកព្រៃឈើ

### ៤.១ ការងារអភិរក្សធនធានជីវចម្រុះនិងសត្វព្រៃ

- ធ្វើការកត់ត្រាសត្វស្លាបនៅតាមតំបន់អភិរក្សសត្វស្លាបសំខាន់ៗចំនួន៤(អាងត្រពាំងថ្ម បឹងព្រែកល្ពៅ អន្លង់ព្រីង កំពង់ធំ និងសៀមរាប) ដែលមានសត្វស្លាបប្រមាណ១៨៩ប្រភេទ (ប្រហែល១០១.៣៨៤ក្បាល)

- ផ្តល់ចំណីដល់សត្វត្មាតចំនួន០៣កន្លែង នៅខេត្តព្រះវិហារ ខេត្តស្ទឹងត្រែង និងខេត្តក្រចេះ ដោយរាប់ឃើញសត្វត្មាតសរុបចំនួនប្រមាណ១២១ក្បាល

- ការពារសម្បុកសត្វត្រដក់តូចចំនួន១១ សត្វត្រយ៉ងចង្កំ ក ស ចំនួន១៦ ត្មាតចំនួន៦ ត្រយ៉ងយក្សចំនួន១ និងរំពេរទន្លេចំនួន៦ នៅខេត្តស្ទឹងត្រែង និងខេត្តក្រចេះ។

### ៤.២ ការងារសហគមន៍ព្រៃឈើ

- បន្តការល្បាតដោយក្រុមល្បាតសហគមន៍ចំនួន២២នាក់ នៅតំបន់ដែនជម្រកក្រពើសំខាន់ៗចំនួន៤គឺនៅអារ៉ែងឆាយរាប តំបន់ស្ពានក្រពើក្នុងឃុំតាតៃលើ ខេត្តកោះកុង និងអូរសោម ខេត្តពោធិ៍សាត់ ដោយរកឃើញក្រពើ១ក្បាលដែលប្រើឧបករណ៍តាមដានវិទ្យុសម្លេង Radio Tracking Device

- ធ្វើការអប់រំផ្សព្វផ្សាយពីសារសំខាន់នៃការអភិរក្សសត្វព្រៃ ច្បាប់ស្តីពីព្រៃឈើ ដោយមានអ្នកចូលរួមសរុបចំនួន ១.៣២៨នាក់ ក្នុងនោះស្ត្រី២៨៥នាក់

- ចុះប្រមូលទិន្នន័យប្រើប្រាស់ដីធ្លីសម្រាប់សាងសង់លំនៅដ្ឋាន និងដីកសិកម្មរបស់ប្រជាពលរដ្ឋភូមិណារុង នៅក្នុងដែនព្រៃការពារព្រះវិហារបានចំនួន១២៨ក្បាលដី ក្នុងនោះលំនៅដ្ឋានចំនួន៥២ក្បាលដី និងដីកសិកម្មចំនួន៧៦ក្បាលដី

- មានភ្ញៀវទេសចរចំនួន៣៥នាក់មកទស្សនាសត្វទោចក្នុងតំបន់អភិរក្សជីវចម្រុះវ៉ុនសៃ-សៀមប៉ាង កំពង់ធំ-សៀមរាប ដោយបានផ្តល់ប្រាក់ចំណូលបន្ថែមដល់សហគមន៍មូលដ្ឋាន

- បន្តសហការជាមួយអង្គការ CSIRO នៃប្រទេសអូស្ត្រាលី បង្កើតចម្ការពូជឈើ អាកាស្យាម៉ង់ស្យូមទំហំ០២ហិកតា នៅស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើក្បាលឆាយ

- បន្តការចុះស្រាវជ្រាវអំពីសត្វល្អិត Leptocybe invasa នៅក្នុងស្ថានីយដាំឈើចំនួន៣ទីតាំង (មានក ស្នួលទ្រេត ក្រសាំង) និងក្រុមហ៊ុន Kamarkara។ ជាលទ្ធផលនៃការស្រាវជ្រាវបានរកឃើញនិងប្រមូលសំណាកនៃសត្វល្អិតនៅក្នុងចម្ការឈើប្រេងខ្យល់ (Eucalyptus K7) ខេត្តបន្ទាយមានជ័យ ហើយក្រុមការងារនឹងបន្តចុះស្រាវជ្រាវលើកទី២ នៅតំបន់ផ្សេងៗទៀត។

### ៤.៣ កសិដ្ឋានចិញ្ចឹម ការបន្ទាត់ពូជស្វាក្តាម និងការសង្គ្រោះសត្វព្រៃ

- ក្នុងខែឧសភា ឆ្នាំ២០១៥នេះ ការងារនៅឧទ្យានសួនសត្វនិងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅកំពុងចិញ្ចឹមនិងថែរក្សា៖ សត្វចំណូលថ្មីចំនួន២៨៨ក្បាល សត្វកើតថ្មីចំនួន៤ក្បាល សត្វដោះលែងចំនួន២៥៤ក្បាល សត្វស្លាប់ចំនួន៨ក្បាល ព្យាបាលសត្វចំនួន៣៩១ក្បាល យកសំណាកទៅពិសោធន៍ចំនួន៨៨ក្បាល ធ្វើឲ្យសន្លប់ចំនួន៨ក្បាល ទម្លាក់សត្វល្អិតចំនួន៨០ក្បាល វះកាត់សាកសពសត្វចំនួន៥ក្បាល សាងសង់ទ្រុងសត្វថ្មីលើចំនួន៩១៨ម² ជួសជុលទ្រុងសត្វនិងអគារផ្សេងៗចំនួន៤ម² ជួសជុលផ្លូវចំនួន១៥.០០០ម² ដាំកូនឈើចំនួន៧ដើម បណ្តុះផ្កាលម្អចំនួន២៦០ដើម និងអប់រំផ្សព្វផ្សាយដល់សិស្សានុសិស្សបានចំនួន២០៩នាក់

- ក្រុមហ៊ុនចំនួន០៧ កំពុងចិញ្ចឹមស្វាក្តាមចំនួន៥៥.១៧៨ក្បាល និងបាននាំចេញកូនស្វាក្តាមចំនួន៣៦ក្បាល។

### ៤.៤ ការងារដាំដើមឈើ

- ទីតាំងរុក្ខទិវាថ្នាក់ជាតិសម្រាប់ឆ្នាំ២០១៥នេះត្រូវបានជ្រើសរើសនៅតំបន់ថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ និងកំពុងរៀបចំទីតាំងប្រារព្ធពិធីសាងសង់វេទិកា និងត្រៀមកូនឈើសម្រាប់ដាំ

- ការដាំឈើជាចម្ការឆ្នាំ២០១៥នៅតាមស្ថានីយផ្សព្វផ្សាយនិងស្តារព្រៃឈើក្បាលឆាយ បន្ទាយស្រី និងអូរបឹងរូង សម្រេចឈូសឆាយដីបានចំនួន៥៥ហិកតា និងថែទាំជួសចម្ការឈើពីឆ្នាំទី១ ដល់ឆ្នាំទី៥ នៅស្ថានីយដាំឈើចំនួន១៦ ដែលមានផ្ទៃដីទំហំចំនួន២.៨១៨ហិកតា ត្រូវបានធ្វើការថែទាំ និងតាមដានព័ត៌មានភ្លើងឆេះព្រៃជាប្រចាំថ្ងៃតាមរយៈផ្កាយរណបរបស់អង្គការ NASA ដោយប្រព័ន្ធ Internet ចំនួន៣ដងក្នុង១ថ្ងៃ និងបញ្ជូនព័ត៌មានទៅតាមបណ្តាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីមានវិធានការទប់ស្កាត់ និងពន្លត់ភ្លើងព្រៃ

- ក្រុមហ៊ុន ស៊ីងបាយអូថេក(ខេមបូឌា) ខូអិលធីឌី បានឈូសឆាយនិងសម្អាតដីទំហំ៥០០ហិកតា និងផលិតកូនឈើប្រភេទអាកាសស្យាម៉ង់ស្យូមចំនួន១.០០០.០០០ដើម និងក្រុមហ៊ុន អូជី (ខេមបូឌា) ផ្លេនថេសិន ហ្វរីស ខមភេនីលីមីធីត បានរៀបចំដាំពិសោធន៍ពូជលើទំហំដី៧ហិកតា

- ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ចបានឈូសឆាយនិងសម្អាតដីសម្រាប់ត្រៀមដាំឈើឆ្នាំ២០១៥ ទំហំសរុប៧០០ហិកតា

- ថ្នាលបណ្ដុះកូនឈើសម្ដេចតេជោ និងថ្នាលបណ្ដុះកូនឈើជាលក្ខណៈគ្រួសារ បណ្ដុះពូជឈើគ្រប់ប្រភេទចំនួន ១.៣២៥.១៥៦ដើម និងចែកចាយជូនកសិករដាំអាស្រ័យផលចំនួន១២២.៥៨៧ដើម

- បន្តថែទាំសួនអាពាហ៍ពិពាហ៍ចំនួន៣៣កន្លែង លើផ្ទៃដីទំហំ៤១៣ហិកតា

- កំពុងថែទាំឡូត៍ស្រាវជ្រាវ កសិ-រុក្ខកម្មទំហំ០៥ហិកតា ដែលមានទីតាំងនៅក្នុងស្ថានីយផ្សព្វផ្សាយនិងស្ដារព្រៃឈើអូរបឹងរូង ខេត្តកំពង់ធំ និងបង្កើតឡូត៍ស្រាវជ្រាវថ្មីទំហំ៥ហិកតាទៀតក្នុងឆ្នាំ២០១៥នេះ។

### ៤.៥ ការងារឧស្សាហកម្មនិងពាណិជ្ជកម្ម

- ផ្ដល់ទិដ្ឋាការអាជ្ញាប័ណ្ណនាំចេញផលិតផលឈើកែច្នៃជូនក្រុមហ៊ុនចំនួន១ ដែលមានបរិមាណចំនួន២០ម៣។

### ៤.៦ ការងារចំណូលព្រៃឈើ

- ផ្ដល់លិខិតបើកផ្លូវដឹកជញ្ជូនផល អនុផលព្រៃឈើ(LP) ជូនក្រុមហ៊ុននិងអតិថិជនមានឈើហ៊ុបមូលសរុបចំនួន ១១.៣៨៤ម៣ កូនឈើចំនួន៨.១០៨ដើម និងអុសចម្រុះចំនួន១៥.៦៤៣ស្ទែរ

- ផ្ដល់លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើសម្រាប់នាំចេញជូនក្រុមហ៊ុនចំនួន២ ស្មើនឹង២សន្លឹក ដែលមានបរិមាណកម្ទេចឈើចំនួន៨៩៩តោន និងដើមចន្ទន៍ក្រស្នាចំនួន២៥ដើម

- ចំណូលពីថ្លៃសួយសារផល អនុផលព្រៃឈើចំនួន៣.០៣៤.៥០២.៤៥៦រៀល និងចំណូលពីសេវាសាធារណៈ ចំនួន៧៦៤.៣០៩.៤១៤រៀល និង២៤.៦១៤,១៩ដុល្លារ។

### ៤.៧ ការងារនីតិកម្មនិងវិវាទ

- សម្រាប់ខែឧសភា ឆ្នាំ២០១៥នេះ មានសំណុំរឿងបទល្មើសព្រៃឈើ សត្វព្រៃ និងបទល្មើសកាប់រានទន្រ្ទានដីព្រៃនៅតាមអង្គភាពរដ្ឋបាលព្រៃឈើមូលដ្ឋានសរុបចំនួន១៣៦ករណី ដោយបញ្ជូនទៅតុលាការចំនួន១០១ករណី និងពិន័យអន្តរការណ៍ចំនួន៣៥ករណី

- ឃាត់ខ្លួនជនជាប់ចោទនិងដកហូតវត្ថុតាងមានដូចជា ឈើមូល-ជ្រុងចំនួន៥៧ម៣ ឈើអារចំនួន២៧២ម៣ ឈើក្រាក់គ្រញូងចំនួន២ម៣ សត្វព្រៃចម្រុះគ្រប់ប្រភេទចំនួន៧៧គ.ក្រនិង២៧៩ក្បាល និងអនុផលព្រៃឈើ ព្រមទាំងសម្ភារផ្សេងៗមួយចំនួនទៀត និងដីព្រៃឈើដែលកាប់រានចំនួន២៣៨ហិកតាត្រូវបានបញ្ជូនសំណុំរឿងទៅតុលាការ និងដកហូតរណារយន្តចំនួន១៣២គ្រឿង

- បាននឹងដំណើរការបញ្ចូលនូវរាល់សំណុំរឿងបទល្មើសព្រៃឈើ-សត្វព្រៃ និងកាប់រានដីព្រៃទៅក្នុងប្រព័ន្ធតាមដានកុំព្យូទ័រ(Case Tracking System-CTS) ដើម្បីរៀបចំឲ្យមានរបៀបរៀបរយទៅតាមប្រព័ន្ធព័ត៌មានទំនើប

- ធ្វើការឆ្លើយតបរហ័សលើព័ត៌មានពាក់ព័ន្ធវិស័យព្រៃឈើដែលមានចុះផ្សាយក្នុងសារព័ត៌មាននានាសរុបចំនួន ៦៤ករណី។ ការចុះផ្សាយនេះបានឆ្លុះបញ្ចាំងពីចំណុចវិជ្ជមាន និងអវិជ្ជមានផងដែរ ហើយអត្ថបទសារព័ត៌មានដែលចុះផ្សាយចំនួន១៤ករណីត្រូវបានជ្រើសរើសរួចបញ្ជូនទៅបណ្ដាខណ្ឌរដ្ឋបាលព្រៃឈើដើម្បីបំភ្លឺ។

## ៥ ផ្នែកជលផល

### ៥.១ អាជីវកម្មនេសាទ

#### ៥.១.១ នេសាទទឹកសាប

- ដាយត្រីក្នុងរដូវនេសាទឆ្នាំ២០១៤-២០១៥ សរុបបានចំនួន១២.២៨៥តោន ស្មើ១០២,៣៨% នៃផែនការ ១២.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៦.៧១៥តោន

- នេសាទគ្រួសារក្នុងដែននេសាទរដូវឆ្នាំ២០១៥ ក្នុងខែចំនួន២០.០០០តោន សរុបបានចំនួន១៥០.២៥០តោន ស្មើ៤២,៩៣% នៃផែនការ៣៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៩.៧៥០តោន

- នេសាទគ្រួសារតាមវាលស្រែក្នុងរដូវឆ្នាំ២០១៥ ក្នុងខែចំនួន៥.០០០តោន សរុបបានចំនួន៣៣.១៥៥តោន ស្មើ២២,១០% នៃផែនការ១៥០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន១១.៨៤៥តោន (មូលហេតុនៃការថយចុះគឺបណ្ដាលមកពីការប្រែប្រួលអាកាសធាតុ)។

#### ៥.១.២ នេសាទសមុទ្រក្នុងឆ្នាំ២០១៥

- ក្នុងខែចំនួន៧.០០០តោន សរុបចំនួន៤៣.២៣៥តោន ស្មើ៣៩,៣០% នៃផែនការ១១០.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន២៦៥តោន។

### ៥.៤ ការនាំចេញផលនេសាទ

- ផលនេសាទស្រស់ ក្នុងខែចំនួន១.០០០តោន សរុបបានចំនួន៤.៨០០តោន ស្មើ៣២% នៃផែនការ១៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន៣០០តោន

- ផលនេសាទកែច្នៃ ក្នុងខែចំនួន៥០០តោន សរុបបានចំនួន២.៧៥០តោន ស្មើ៥៥% នៃផែនការ៥.០០០តោន ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ កើនឡើងចំនួន២៥០តោន។

### ៥.៥ ការត្រួតពិនិត្យនិងបង្ក្រាបបទល្មើស

- កំណត់ហេតុបទល្មើស សរុបចំនួន២៨៥ករណី ដែលកើតមាននៅតំបន់ទឹកសាប២៦០ករណី និងតំបន់សមុទ្រ ២៥ករណី ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន៧៦១ករណី គឺតំបន់ទឹកសាបថយចុះ៧៥០ករណី និងតំបន់សមុទ្រថយចុះ១១ករណី។ សមត្ថកិច្ចជំនាញកំពុងបន្តជំរុញការចុះត្រួតពិនិត្យនិងមានវិធានការដើម្បីលុបបំបាត់បទល្មើសនេសាទតាមគ្រប់រូបភាព។

### ៥.៦ ការប្រមូលថវិកា

- ចំណូលពីវិស័យជលផល ក្នុងខែចំនួន២៨១.៧៥៥.០០០រៀល សរុបបានចំនួន១.៦១៩.៣២៣.៥០០រៀល ស្មើ៥៣,៩៨% នៃផែនការ៣.០០០.០០០.០០០រៀល ប្រៀបធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៤ ថយចុះចំនួន ២៤៧.០៧៥.២៥០រៀល។

## ៦ ផ្នែកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា

- ចុះប្រមូលទិន្នន័យ និងពិសោធន៍លើការកៀរពង្រាបដីដោយប្រព័ន្ធឡាស៊ែ នៅខេត្តព្រះវិហារ និងខេត្តតាកែវ ប្រមូលព័ត៌មានអំពីការដាំដុះដំណាំស្វាយ នៅខេត្តកំពង់ស្ពឺ និងខ្សែសង្វាក់តម្លៃរបស់ផលិតកម្មដំណាំស្រូវ នៅខេត្តសៀមរាប

- ចែកសម្ភារពិសោធន៍ និងរៀបចំពិសោធន៍ស្រែបង្ហាញ នៅខេត្តកំពត

- ដឹកម៉ាស៊ីនសម្ងួតគ្រាប់ស្រូវសម្រាប់ធ្វើពិសោធន៍ដល់អ្នកសហការ និងរៀបចំដាំដុះស្រូវពិសោធន៍ នៅខេត្តបាត់ដំបង ខេត្តតាកែវ និងខេត្តកំពត។

## ៧ ផ្នែករដ្ឋបាល

- ទទួលលិខិតពីក្រសួងនិងស្ថាប័ននានា ក្នុងខែចំនួន៤២៤ច្បាប់ សរុបចំនួន២.២៥៧ច្បាប់ ទទួលពីអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២២៥ច្បាប់ សរុបចំនួន១.៤៤២ច្បាប់ និងទទួលពីរាជធានី ខេត្ត ក្នុងខែចំនួន៩៧ច្បាប់ សរុបចំនួន ៥២០ច្បាប់ និងចាត់ចែងបន្តតាមចរន្តរដ្ឋបាល

- បញ្ជូនឯកសារនិងលិខិតទៅស្ថាប័នផ្សេងៗ អង្គភាពក្រោមឱវាទ និងរាជធានី ខេត្ត ក្នុងខែចំនួន៦៤៦ច្បាប់ សរុបចំនួន៣.២១៥ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន១៥ច្បាប់ សរុបចំនួន២២៩ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៤ច្បាប់ សរុបចំនួន១៣៦ច្បាប់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៨៧នាក់ នារីចំនួន១.៣៥៨នាក់ ស្មើនឹង២០% រួមមាន៖

  + អង្គភាពថ្នាក់កណ្តាលចំនួន៤.១៣០នាក់ ក្នុងនោះនារីចំនួន៧៨២នាក់ ស្មើនឹង១៩%

  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៥៧នាក់ ក្នុងនោះនារីចំនួន៥៧៦នាក់ ស្មើនឹង២២%

- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០៩នាក់ ក្នុងនោះបោះបង់ការងារចំនួន០១នាក់ សុំលាឈប់ពីការងារចំនួន០៤នាក់ និងមរណភាពចំនួន០៤នាក់

- ចេញច្បាប់សម្រាកប្រចាំឆ្នាំចំនួន០៥នាក់ ច្បាប់ព្យាបាលជំងឺចំនួន០៥នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៤នាក់

- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ ផ្ទេរចូលក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៦នាក់

- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១៧នាក់ និងចូលធ្វើការងារវិញចំនួន០៤នាក់

- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៣០នាក់ និងក្នុងប្រទេសចំនួន០១នាក់

សរុបចំនួន៣.២១៥ច្បាប់ ប្រកាស សេចក្តីសម្រេច និងសារាចរ ក្នុងខែចំនួន១៥ច្បាប់ សរុបចំនួន២២៩ច្បាប់ និងចម្លងចែកទៅអង្គភាពក្រោមឱវាទ ក្នុងខែចំនួន២៤ច្បាប់ សរុបចំនួន១៣៦ច្បាប់

- ក្រៅពីនេះគឺមានការទទួលរៀបចំកិច្ចប្រជុំផ្ទៃក្នុងរបស់ក្រសួងនិងការទទួលភ្ញៀវជាតិ អន្តរជាតិ ការចូលរួមរៀបចំពិធីបុណ្យជាតិ អន្តរជាតិ។ល។

## ៨ ផ្នែកបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងទស្សនកិច្ចសិក្សាក្រៅប្រទេស

- ក្របខ័ណ្ឌមន្ត្រីរាជការសរុបទូទាំងប្រទេសមានចំនួន៦.៧៨៧នាក់ នារីចំនួន១.៣៥៨នាក់ ស្មើនឹង២០% រួមមាន៖
  + អង្គភាពថ្នាក់កណ្តាលចំនួន៤.១៣០នាក់ ក្នុងនោះនារីចំនួន៧៨២នាក់ ស្មើនឹង១៩%
  + អង្គភាពថ្នាក់រាជធានី ខេត្តចំនួន២.៦៥៧នាក់ ក្នុងនោះនារីចំនួន៥៧៦នាក់ ស្មើនឹង២២%
- ប្រកាសលុបឈ្មោះមន្ត្រីចេញពីក្របខ័ណ្ឌចំនួន០៩នាក់ ក្នុងនោះបោះបង់ការងារចំនួន០១នាក់ សុំលាឈប់ពីការងារចំនួន០៤នាក់ និងមរណភាពចំនួន០៤នាក់
- ចេញច្បាប់សម្រាកប្រចាំឆ្នាំចំនួន០៥នាក់ ច្បាប់ព្យាបាលជំងឺចំនួន០៥នាក់ និងច្បាប់សម្រាកមាតុភាពចំនួន០៤នាក់
- ប្រកាសផ្ទេរមន្ត្រីរាជការចេញក្រៅក្រសួងចំនួន០១នាក់ ផ្ទេរចូលក្រសួងចំនួន០១នាក់ និងផ្ទេរចេញ-ចូលផ្ទៃក្នុងក្រសួងចំនួន០៦នាក់
- ប្រកាសព្យួរការងារមន្ត្រីរាជការចំនួន១៧នាក់ និងចូលធ្វើការងារវិញចំនួន០៤នាក់
- ថ្នាក់ដឹកនាំ មន្ត្រីរាជការក្រោមឱវាទបានទៅចូលរួមវគ្គបណ្តុះបណ្តាលក្រៅប្រទេសចំនួន៣០នាក់ និងក្នុងប្រទេសចំនួន០១នាក់
- ពិនិត្យនិងកែតម្រូវលើការប្រែប្រួលនៃស្ថានភាពបុគ្គលិក និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការគ្រប់អង្គភាពថ្នាក់កណ្តាល បញ្ចូលក្នុងតារាងបៀវត្សថ្មីតាមប្រព័ន្ធព័ត៌មានវិទ្យា។

## ៩ ផ្នែកសហប្រតិបត្តិការអន្តរជាតិ

- មន្ត្រីចំនួន៥៥រូប ចូលរួម និងសហការរៀបចំកិច្ចប្រជុំលើកទី៦របស់ក្រុមការងារជំនាញស្តីពីការអនុវត្តកសិកម្មល្អ កិច្ចប្រជុំថ្នាក់តំបន់ និងអន្តរជាតិរបស់ក្រុមការងារបច្ចេកទេសក្រពើ កិច្ចប្រជុំរបស់មជ្ឈមណ្ឌលអាស៊ានសម្រាប់ក្រុមប្រឹក្សាអភិវឌ្ឍន៍សហគមន៍កសិកម្មលើកទី២២ និងកិច្ចប្រជុំលើកទី១៧ របស់ក្រុមការងារអាស៊ានស្តីពីសហគមន៍កសិកម្ម នៅខេត្តសៀមរាប
- បានចាត់បញ្ជូនថ្នាក់ដឹកនាំក្រសួង និងមន្ត្រីរាជការក្រោមឱវាទក្រសួងទៅចូលរួមប្រជុំ សន្និសីទ សិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនកិច្ចសិក្សាសរុបចំនួន៥៩នាក់ នៅក្នុងប្រទេសចំនួន១៣។

## ១០ ការអប់រំ បណ្តុះបណ្តាលកសិកម្ម

### ១០.១ សាលាជាតិកសិកម្មព្រែកលៀប

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបចំនួន១.២២៣នាក់(ស្រី៣៩៦នាក់) ក្នុងនោះនិស្សិតបរិញ្ញាចំនួន១.០១៥នាក់(ស្រី៣៤៦នាក់) និងនិស្សិតបរិញ្ញារងចំនួន២០៨នាក់(ស្រី៤៦នាក់) ដែលកំពុងសិក្សាលើមុខជំនាញវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ផ្សព្វផ្សាយនិងអភិវឌ្ឍន៍ជនបទ សាកវប្បកម្ម សេដ្ឋកិច្ចនិងគ្រប់គ្រងកសិកម្ម កសិឧស្សាហកម្ម និងសុរិយោដី។ សហការជាមួយក្រសួងអប់រំយុវជននិងកីឡាក្នុងការកែលម្អកម្មវិធីសិក្សាក្នុងគោលបំណង ប្រែក្លាយសាលាជាតិកសិកម្មព្រែកលៀបទៅជាសាកលវិទ្យាល័យជាតិព្រែកលៀប។ សាលាជាតិបាននឹងកំពុងបំពាក់ប្រព័ន្ធអ៊ីនធឺណែត និងដំឡើងស៊ែវ័រ(Sever) ព្រមទាំងសហការយ៉ាងជិតស្និទ្ធជាមួយភាគីចិនដែលកំពុងសាងសង់មន្ទីរពិសោធន៍ដើម្បីទាញភ្លើងនិងទឹកចូលអគារ។

### ១០.២ សាលាជាតិកសិកម្មកំពង់ចាម

និស្សិតដែលកំពុងសិក្សានាឆ្នាំសិក្សា២០១៤-២០១៥ សរុបមានចំនួន១.២១៨នាក់(ស្រី៤៥៨នាក់) រួមមាន៖

- និស្សិតអាហារូបករណ៍សរុប៨៤៨នាក់ (ស្រី៣៤១នាក់) ក្នុងនោះថ្នាក់បរិញ្ញាវិទ្យាសាស្ត្រកសិកម្ម៦៩០នាក់(ស្រី២៤១នាក់) និងថ្នាក់បរិញ្ញារងបច្ចេកទេសកសិកម្ម១៥៨នាក់(ស្រី១០០នាក់) ដែលកំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រនិងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល ដំណាំកៅស៊ូ សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ
- និស្សិតសិក្សាបង់ថ្លៃ២២៨នាក់ (ស្រី៦៧នាក់) ថ្នាក់បរិញ្ញាចំនួន២១៧នាក់(ស្រី៦៦នាក់) និងថ្នាក់បរិញ្ញារងចំនួន១១នាក់ (ស្រី១នាក់) កំពុងសិក្សាមុខជំនាញក្សេត្រសាស្ត្រ វិទ្យាសាស្ត្រ និងវេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រជលផល

ដំណាំកៅស៊ូ និងសេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ។ សាលាជាតិបានលើកគម្រោងចំនួន១១គម្រោងស្នើសុំថវិកាសម្រាប់ធ្វើការស្រាវជ្រាវលើប្រធានបទការពិសោធន៍កសិកម្ម វារីវប្បកម្ម បសុវប្បកម្ម និងសង្គមជនបទ។

**១០.៣ សាកលវិទ្យាល័យភូមិន្ទកសិកម្ម**

និស្សិតកំពុងសិក្សាមានចំនួនសរុប៥.៩៧៧នាក់(ស្រី១.៨០០នាក់) ចែកចេញជា១០មហាវិទ្យាល័យ គឺមហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រកៅស៊ូ វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ វិទ្យាសាស្ត្រព្រៃឈើ វិទ្យាសាស្ត្រជលផល វិស្វកម្មកសិកម្ម កសិ-ឧស្សាហកម្ម សេដ្ឋកិច្ចកសិកម្មនិងអភិវឌ្ឍន៍ជនបទ និងមហាវិទ្យាល័យរៀបចំដែនដីនិងរដ្ឋបាលដីធ្លី ដែលសិក្សាតាមកម្មវិធីថ្នាក់បរិញ្ញារង ថ្នាក់បរិញ្ញាវិទ្យាសាស្ត្រ និងសាលាក្រោយឧត្តមបានបណ្តុះបណ្តាលលើកម្មវិធីបរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត។ សាកលវិទ្យាល័យបានរៀបចំធ្វើសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធស្តីពីការអភិវឌ្ឍកម្មវិធីសិក្សារបស់មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម វិទ្យាសាស្ត្រសត្វ វេជ្ជសាស្ត្រសត្វ និងកសិឧស្សាហកម្មក្រោមជំនួយរបស់គម្រោងSPS និងបានធ្វើសិក្ខាសាលាជូននិស្សិតស្តីពីឱកាសទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យ Purdue University សហរដ្ឋអាមេរិក និងឱកាសទទួលអាហារូបករណ៍ពីគម្រោង Lotus+ ទៅសិក្សានៅសាកលវិទ្យាល័យនៃសហភាពអឺរ៉ុប។ បញ្ជូនសាស្ត្រាចារ្យចូលរួមប្រជុំការងារសហប្រតិបត្តិការបច្ចេកទេសចំនួន០៤រូប នៅប្រទេសថៃ ឥណ្ឌូនេស៊ី និងនៅប្រទេសជប៉ុន។ ក្នុងកម្មវិធីផ្លាស់ប្តូរនិស្សិត សាកលវិទ្យាល័យបានទទួលនិស្សិតចំនួន៣៥នាក់ ពីសាកលវិទ្យាល័យ Duksoung Women University ប្រទេសកូរ៉េ និងបានបញ្ជូននិស្សិត២នាក់ ទៅចូលរួមកម្មវិធីបោះជំរុំនៅប្រទេសថៃ លើប្រធានបទ "សេដ្ឋកិច្ចអាស៊ាន" ផងដែរ ។

គ្រឹះស្ថានឧត្តមសិក្សាកសិកម្មទាំង៣ខាងលើ តែងតែបញ្ជូននិស្សិតឲ្យចុះធ្វើកម្មសិក្សានៅតាមអង្គភាពជំនាញនៅទីវាល និងតាមបណ្តាក្រុមហ៊ុនមួយចំនួនដូចខែមុនៗដែរដើម្បីផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងក៏ដូចជាការបង្ហាត់ឲ្យចេះកែច្នៃកសិផលមួយចំនួនសម្រាប់ការធ្វើកសិ-ពាណិជ្ជកម្ម រួមទាំងការពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូឲ្យកាន់តែទូលំទូលាយ។

## III-សេចក្តីសន្និដ្ឋាននិងវាយតម្លៃ

ជារួម នៅក្នុងខែឧសភានេះ ស្ថានភាពការងារបង្កបង្កើនផលស្រូវរដូវវស្សាឆ្នាំ២០១៥មានសភាពលឿនជាងឆ្នាំមុនប្រមាណ៣៥.១៧៧ហិកតា។ បច្ចុប្បន្ន ប្រជាកសិករបាននិងកំពុងខិតខំជំរុញការរៀបចំដី ភ្ជួររាស់ សាប ព្រោះ និងដកស្ទូងដើម្បីឲ្យទាន់រដូវកាលដាំដុះ។ ដោយឡែក ចំពោះជំងឺឆ្លងសត្វ និងជំងឺឆ្លងរាតត្បាតផ្សេងៗលើសត្វពាហនៈពុំមានចោទជាបញ្ហាទេ។ គួរកត់សម្គាល់ថា ក្នុងខែកន្លងមកនេះក្រសួងបានរៀបចំសិក្ខាសាលាប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការនូវ "គោលនយោបាយផ្សព្វផ្សាយកសិកម្មនៅកម្ពុជា" ប្រកបដោយជោគជ័យ។

ដោយឡែក ការគ្រប់គ្រងធនធានធម្មជាតិ ព្រៃឈើ និងជលផល កំពុងស្ថិតនៅតែជាប្រធានបទអាទិភាព ហើយដែលអង្គភាពជំនាញជាសេនាធិការនៅតែខិតខំបន្តពង្រឹងការអនុវត្តច្បាប់ និងបទដ្ឋានផ្សេងៗជាធរមានយ៉ាងយកចិត្តទុកដាក់ ដោយជំរុញការចុះត្រួតពិនិត្យនិងចាត់វិធានការជាក់ស្តែងដើម្បីលុបបំបាត់បទល្មើសព្រៃឈើនិងជលផលតាមគ្រប់រូបភាព។ លើសពីនេះទៅទៀត ផ្នែកសេវាកម្ម ដំណើរការនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ កិច្ចការសវនកម្ម ការចុះធ្វើអធិការកិច្ចតាមបណ្តាអង្គភាពក្រោមឱវាទ កិច្ចសហប្រតិបត្តិការអន្តរជាតិ ការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងការគាំទ្រផ្សេងៗនៅតែបន្តអនុវត្តភារកិច្ចរបស់ខ្លួនក្នុងស្មារតីទទួលខុសត្រូវដោយសម្រេចបាននូវលទ្ធផលការងារតាមផ្នែកនីមួយៗបានល្អប្រសើរស្របតាមគោលការណ៍និងទិសដៅរបស់រាជរដ្ឋាភិបាល។

## IV- ទិសដៅអនុវត្តបន្ត

**១.ផ្នែកដាំដុះ :**

- តាមដាននិងអន្តរាគមន៍ចំពោះការផ្ទុះរាលដាល និងការបំផ្លាញដោយសត្វល្អិតជាយថាហេតុចំពោះដំណាំកសិកម្មផ្សេងៗនិងការជំរុញការងារបង្កបង្កើនផលដើមរដូវវស្សានេះឲ្យបានទាន់រដូវកាលដាំដុះ
- តាមដានចលនានាំចេញស្រូវនិងថ្លៃស្រូវ ជាពិសេសតាមច្រកព្រំដែននានា
- បន្តជំរុញអប់រំផ្សព្វផ្សាយឱ្យប្រជាកសិករដាំដំណាំផ្សេងទៀត ឬប្រើប្រាស់ពូជស្រូវសមស្របជាមួយនឹងការប្រើប្រាស់ទឹកដោយប្រសិទ្ធភាព ជាពិសេសចំពោះខេត្តដែលមានអគុល្យភាពស្បៀង (អង្គរ) ដោយជំរុញកសិករឲ្យឆ្លៀតឱកាស

ដាំដំណាំរួមផ្សំ ដូចជា ៖ ពោត ដំឡូង បន្លែ សណ្តែក។ល។ និងកាត់បន្ថយការចំណាយថ្លៃដើមឲ្យបានច្រើនដើម្បីផ្តល់កម្រៃបន្ថែមជួយលើកកម្ពស់សេដ្ឋកិច្ចគ្រួសារ

- ពិនិត្យ ពង្រឹងឡើងវិញ ដើម្បីត្រៀមលក្ខណៈមានដូចជាៈ ស្រូវពូជ ពូជបន្លែ មធ្យោបាយ និងសម្ភារនានាសម្រាប់អន្តរាគមន៍នៅពេលមានគ្រោះមហន្តរាយជាយថាហេតុ ការទប់ទល់ជំងឺឬសត្វល្អិតចង្រៃបំផ្លាញដំណាំផ្សេងៗ ព្រមទាំងបន្តរៀបចំពង្រឹងសហគមន៍កសិកម្ម ការធ្វើផលិតកម្មកសិកម្មតាមកិច្ចសន្យាឆ្ពោះទៅរកការធ្វើកសិ-ពាណិជ្ជកម្ម

- អង្កេតទូទៅអំពីស្ថានភាពជំងឺគ្រប់ឡូត៍ពិសោធន៍កូនកៅស៊ូ ត្រួតពិនិត្យជំងឺកៅស៊ូ និងបន្តការផ្សព្វផ្សាយបច្ចេកទេសទៅតាមបណ្តាខេត្តដែលមានសក្តានុពលកៅស៊ូ

- ចុះពិនិត្យនៅតាមបណ្តាមន្ទីរពិសោធន៍យថាប្រភេទនិងរោងចក្រកែច្នៃកៅស៊ូ

- បន្តស្រាវជ្រាវការដាំដុះសាកល្បងកូនកៅស៊ូប្រភេទ "Invitro" និងបន្តផ្សព្វផ្សាយអំពីបច្ចេកទេសដ៏មានសារសំខាន់នេះក្នុងក្របខណ្ឌនៃគម្រោងធម្មនិយាមកម្មច្បារពូជកៅស៊ូនៅកម្ពុជា។

**២.ផ្នែកផលិតកម្មនិងបសុព្យាបាល** :

- បន្តចាត់វិធានការដោយសហការជាមួយស្ថាប័ននិងអាជ្ញាធរមូលដ្ឋាន ដើម្បីចុះពិនិត្យនិងតាមដានជាបន្តលើសភាពការណ៍ជំងឺសត្វ និងចាត់ក្រុមការងារចុះអប់រំណែនាំនិងជំរុញអង្គភាពជំនាញក្រោមឱវាទ និងមន្ទីរកសិកម្មរាជធានី-ខេត្ត ស្រុក ដើម្បីត្រៀមនិងចាក់ថ្នាំវ៉ាក់សាំងបង្ការការពារជំងឺសត្វ ការធ្វើអនាម័យសត្វ ការព្យាបាល សង្គ្រោះសត្វ និងវិធានការអន្តរាគមន៍តាមជាក់ស្តែង។ ទន្ទឹមនឹងនោះ ត្រូវធ្វើការអប់រំណែនាំដល់ប្រជាកសិករឲ្យបង្កើនការថែទាំបន្ថែមទៀត ព្រមទាំងចាត់ក្រុមអន្តរាគមន៍ឲ្យចុះជាប់ជាប្រចាំ ដើម្បីទប់ស្កាត់បទល្មើសចលនាសត្វដោយខុសច្បាប់នៅតាមបណ្តារាជធានី ខេត្ត ជាពិសេសខេត្តនៅជាប់ព្រំដែន

- រៀបចំគម្រោងបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមសត្វនៅតាមបណ្តារាជធានី ខេត្ត និងបង្កើនការលើកកម្ពស់ការចិញ្ចឹមសត្វគ្រប់ប្រភេទនៅក្នុងស្រុកឲ្យបានទូលំទូលាយ

- ថែទាំសុខភាព តាមដានជំងឺសត្វ និងមានវិធានការអន្តរាគមន៍តាមការចាំបាច់

- ត្រៀមលក្ខណៈចុះអនុវត្តវិធានបសុពេទ្យនៅកន្លែងផ្ទុះជំងឺនិងកន្លែងដែលមានការឆ្លងរាលដាលជំងឺផ្តាសាយបក្សី H5N1 និងជំងឺផ្តាសាយ H7N9

- ពង្រឹងត្រួតពិនិត្យចរាចរណ៍សត្វនិងផលិតផលសត្វតាមទីស្នាក់ការត្រួតពិនិត្យ ច្រកទ្វារអន្តរជាតិ ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ

- ជំរុញការផ្សព្វផ្សាយការបង្កាត់ពូជសត្វតាមលក្ខណៈសិប្បនិម្មិតនិងដំណាំចំណីសត្វនៅទូទាំងប្រទេស

- ចុះផ្សព្វផ្សាយអំពីលក្ខណៈនិងសញ្ញាណជំងឺជ្រូកត្រចៀកខៀវ ប៉េស្ត និងវិធានការទប់ស្កាត់នៅតាមរាជធានី ខេត្ត

- ចុះតាមដានសកម្មភាពចាក់ថ្នាំការពារជំងឺគោ ក្របី និងពិនិត្យស្ថានភាពជំងឺសត្វនៅតាមរាជធានី ខេត្ត ពិសេសការពង្រឹងការអនុវត្តវិធានបច្ចេកទេសនៅតាមបណ្តាសត្តឃាតដ្ឋានឲ្យបានសមស្របតាមនីតិវិធី

- ជំរុញការស្រាវជ្រាវលើការងារផលិតកម្មសត្វនិងបសុព្យាបាល។

**៣.ផ្នែកព្រៃឈើ** :

- បន្តជំរុញដាក់ឲ្យដេញថ្លៃជាសាធារណៈចំពោះឈើដែលបានរឹបអូសតាមសាលក្រមរបស់តុលាការ និងតាមការពិន័យអន្តរការណ៍

- បន្តតាមដានត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីផ្នែកព្រៃឈើ តាមរយៈការលើកកម្ពស់កម្រិតជីវភាពប្រជាជននៅតាមតំបន់ជនបទ ស្ថិរភាពធនធានព្រៃឈើ ការពង្រឹងនិងពង្រីកសហគមន៍ព្រៃឈើឲ្យបានកាន់តែទូលំទូលាយ ដោយរៀបចំបែបបទទទួលស្គាល់ជាផ្លូវការ និងអភិវឌ្ឍសហគមន៍ព្រៃឈើថ្មីៗ ព្រមទាំងអប់រំផ្សព្វផ្សាយដល់ប្រជាសហគមន៍ឲ្យងាកមកធ្វើកសិកម្មចម្រុះបន្ថែមទៀតដោយមិនពឹងអាស្រ័យទៅលើតែផល អនុផលព្រៃឈើនោះឡើយ

- បន្តការដាំកូនឈើ និងដាំឈើឱ្យបានទូលំទូលាយតាមផែនការដែលបានគ្រោងទុក និងការត្រៀមលក្ខណៈដើម្បីរៀបចំពិធីបុណ្យរុក្ខទិវា នៅថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៥ នៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ

- បន្តសហការជាមួយដៃគូនានាអនុវត្តគម្រោងការបណ្តុះបណ្តាល ដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលព្រៃឈើនិងភាគីពាក់ព័ន្ធ តាមរយៈការបង្កើតប្រព័ន្ធចែករំលែកព័ត៌មាន និងបង្កើនសកម្មភាពសិក្សាស្រាវជ្រាវនិងអភិវឌ្ឍព្រៃឈើសត្វព្រៃ និងបន្តពង្រីកការអនុវត្តគម្រោងការស្រាវជ្រាវនានាជាមួយដៃគូអភិវឌ្ឍន៍

- បន្តបង្កើនសកម្មភាពសិក្សាស្រាវជ្រាវ និងអភិវឌ្ឍព្រៃឈើ សត្វព្រៃ តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពស្រាវជ្រាវ

- កំណត់តំបន់ព្រៃឈើរេចរឹលឲ្យបានច្បាស់ ដើម្បីធ្វើការស្តារព្រៃឈើឡើងវិញឲ្យក្លាយជាតំបន់ព្រៃឈើមានតម្លៃពាណិជ្ជកម្មដោយធ្វើការដាំដុះប្រភេទឈើប្រណិតមានតម្លៃនិងថែរក្សាការពារចម្ការព្រៃពូជ ព្រមជាមួយការប្រមូលពូជឈើ

- បន្តបង្កើនកិច្ចសហប្រតិបត្តិការល្អជាមួយស្ថាប័ន សមត្ថកិច្ចជំនាញ និងភាគីពាក់ព័ន្ធនានា ជាពិសេសអ្នកសារព័ត៌មាននិងព្រះរាជអាជ្ញាឲ្យជួយគាំទ្រដល់ការងារពង្រឹងការអនុវត្តច្បាប់ប្រកបដោយតម្លាភាពនិងប្រសិទ្ធភាពខ្ពស់ និងពង្រឹងប្រព័ន្ធឆ្លើយតបរហ័ស

- ពង្រឹងការអនុវត្តច្បាប់ស្តីពីព្រៃឈើនិងបទបញ្ជារបស់រាជរដ្ឋាភិបាលលេខ០១ និង០២។

**៤.ផ្នែកជលផល** :

- ពង្រឹងសមត្ថភាពមន្ត្រីរដ្ឋបាលជលផលគ្រប់លំដាប់ថ្នាក់និងអ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងផ្នែកជលផល

- ពង្រឹងកិច្ចសហការជាប់ជាប្រចាំជាមួយអាជ្ញាធរដែនដី គណៈបញ្ជាការឯកភាពរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសជលផល

- ជំរុញពង្រឹងសមត្ថភាពសហគមន៍នេសាទ ដើម្បីលើកកម្ពស់ការទទួលខុសត្រូវនិងភាពជាម្ចាស់លើការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទរបស់ខ្លួនដោយអនុវត្តយន្តការ "សហគមន៍នេសាទគ្មានបទល្មើសជលផល"

- បន្តស្រាវជ្រាវដកហូត និងបោះបង្គោលដីព្រៃលិចទឹកដែលកាន់កាប់អនាធិបតេយ្យដោយសហការជាមួយអាជ្ញាធរពាក់ព័ន្ធ

- រៀបចំផ្លូវភ្លើងនិងប៉មយាមសម្រាប់ត្រួតពិនិត្យភ្លើងឆេះព្រៃ

- បន្តបង្កើត និងពង្រឹងសហគមន៍ស្រះជម្រកត្រីបន្ថែមទៀតឲ្យបានគ្រប់ឃុំ

- ការត្រៀមលក្ខណៈដើម្បីរៀបចំទិវាមច្ឆជាតិ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៥ នៅឃុំទួលព្រះឃ្លាំង ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម

- ជំរុញការអនុវត្តផែនការសកម្មភាពឆ្នាំ២០១៥ ដើម្បីបង្កើនផលនេសាទទឹកសាប (នេសាទដាយត្រី នេសាទគ្រួសារក្នុងដែននេសាទ នេសាទគ្រួសារក្នុងវាលស្រែ) អាជីវកម្មនេសាទសមុទ្រ វារីវប្បកម្ម (ការចិញ្ចឹមត្រី បង្គា ការចិញ្ចឹមក្រពើ ការផលិតកូនត្រីពូជ) ការកែច្នៃផលនេសាទ (ទឹកសាប ទឹកប្រៃ និងការផលិតទឹកត្រី) ការនាំចេញផលនេសាទ និងការបង្កើនផលចំណូលថវិកាជាតិ។

**៥.ផ្នែកពាក់ព័ន្ធផ្សេងៗ** :

- បន្តចុះទប់ស្កាត់បទល្មើសផ្សេងៗពាក់ព័ន្ធការអនុវត្តច្បាប់ ស្តីពីការគ្រប់គ្រងថ្នាំកសិកម្មនិងជីកសិកម្មនៅតាមបណ្តាខេត្ត រាជធានី។ ជំរុញអនុវត្តកម្មវិធីផ្សព្វផ្សាយ ការយល់ដឹងពាក់ព័ន្ធការគ្រប់គ្រងការធ្វើអាជីវកម្ម ការកាន់កាប់ ប្រើប្រាស់សម្ភារកសិកម្មឱ្យបានកាន់តែទូលំទូលាយដល់មន្ត្រី អាជីវករ និងអ្នកប្រើប្រាស់សម្ភារកសិកម្ម

- ពង្រឹងការងារបញ្ជីការគណនេយ្យនៅតាមបណ្តាអង្គភាពក្រោមឱវាទនិងបណ្តាមន្ទីរកសិកម្មខេត្ត រាជធានី ក៏ដូចជាការតម្រង់ទិសទៅរកការអនុវត្តថវិកាតាមកម្មវិធីពេញលេញនៅឆ្នាំ២០១៥ ក្នុងក្របខ័ណ្ឌកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈឲ្យមានប្រសិទ្ធភាព និងការបន្តរៀបចំផែនការថវិកាសម្រាប់ឆ្នាំ២០១៦

- បន្តចុះពិនិត្យផ្ទាល់ដល់ក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច ដើម្បីមានមូលដ្ឋានរាយការណ៍ឲ្យបានច្បាស់លាស់

សម្រាប់ផ្ទៀងផ្ទាត់ទៅនឹងការអនុវត្តផែនការមេ និងយកចិត្តទុកដាក់លើការប្រមូលចំណូលបង់ចូលថវិកាជាតិឲ្យបានសមស្របតាមនីតិវិធី

- បន្តលើកកម្ពស់គុណភាពនិងប្រសិទ្ធភាពនៃការស្រាវជ្រាវអប់រំផ្សព្វផ្សាយ តាមរយៈការផលិតសម្ភារនិងឯកសារបច្ចេកទេសតាមផ្នែកនីមួយៗក្នុងស្មារតីទទួលខុសត្រូវព្រមទាំងពង្រីកកិច្ចសហប្រតិបត្តិការល្អជាមួយគ្រប់ដៃគូទាំងអស់ក្នុងការពង្រឹងសមត្ថភាពមន្ត្រីរាជការ ការចូលរួមគ្រប់សកម្មភាពតាមផ្នែកទាំងក្នុងនិងក្រៅប្រទេសឲ្យបានទូលំទូលាយ។ ទន្ទឹមនឹងនេះ ក៏ត្រូវគិតគូរអំពីការបញ្ចូលការងារយេនឌ័រនិងអាហារូបត្ថម្ភទៅក្នុងសកម្មភាពសំខាន់តាមផ្នែកនីមួយៗផងដែរ

- បន្តចុះធ្វើអធិការកិច្ចនិងកិច្ចការសវនកម្មតាមបណ្តាអង្គភាពក្រោមឱវាទតាមផែនការឆ្នាំដែលបានគ្រោងទុក និងតាមសកម្មភាពជាក់ស្តែង

- ការត្រៀមរៀបចំប្រារព្ធទិវាពិភពលោកទប់ស្កាត់រហោស្ថានកម្ម ឬឱនភាពដីនៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៥ នៅឃុំរស្មីសាមគ្គី ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ

- ពង្រឹងការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សឲ្យបានសមស្របទៅតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការនៃព្រះរាជាណាចក្រកម្ពុជា និងយកចិត្តទុកដាក់ក្នុងការត្រួតពិនិត្យនិងចាត់វិធានការសមស្របដើម្បីពង្រឹងការគ្រប់គ្រងមន្ត្រីរាជការឲ្យបានហ្មត់ចត់

-ជំរុញការយកចិត្តទុកដាក់រៀបចំច្បាប់ លិខិតបទដ្ឋានគតិយុត្ត អត្ថបទក្រោមច្បាប់ ផែនការយុទ្ធសាស្ត្រ ស្តង់ដារ និងគោលការណ៍ព្រមទាំងពង្រឹងសមត្ថភាពធនធានមនុស្ស សមត្ថភាពពាក់ព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធនៅតាមអង្គភាពក្រោមឱវាទ ដើម្បីលើកកម្ពស់វិស័យកសិកម្មនៅកម្ពុជាក្នុងការត្រៀមលក្ខណៈសម្រាប់ការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ាននៅចុងឆ្នាំ២០១៥ និងនាពេលអនាគត។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មិថុនា ឆ្នាំ២០១៥

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

យុន្ត ត្ញូថន